Tips of the Week



(Muharram & Fasting on 'Ashura' Day)

(Muharram & Fasting on ‘Ashura’ Day)

إِنَّ عِدَّةَ الشُّهُورِ عِنْدَ اللَّهِ اثْنَا عَشَرَ شَهْرًا فِي كِتَابِ اللَّهِ يَوْمَ خَلَقَ السَّمَاوَاتِ وَالْأَرْضَ مِنْهَا أَرْبَعَةٌ حُرُمٌ ۚ ذَٰلِكَ الدِّينُ الْقَيِّمُ ۚ فَلَا تَظْلِمُوا فِيهِنَّ أَنْفُسَكُمْ ۚ وَقَاتِلُوا الْمُشْرِكِينَ كَافَّةً كَمَا يُقَاتِلُونَكُمْ كَافَّةً ۚ وَاعْلَمُوا أَنَّ اللَّهَ مَعَ الْمُتَّقِينَ

سورة التوبة:36

ពិតប្រាកដណាស់ ចំនួនខែរបស់អល់ឡោះមានដប់ពីរខែ និងបានចារនៅក្នុងគម្ពីររបស់អល់ឡោះ(ឡាវហុលម៉ះហ្វ៊ូស)តាំងពី ថ្ងៃដែលទ្រង់បានបង្កើតមេឃជាច្រើនជាន់ និងផែនដីមកម្លេះ។ ក្នុង នោះគឺមានបួនខែដែលត្រូវបានគេហាមឃាត់(មិនឱ្យធ្វើសង្គ្រាម)។ នោះហើយគឺជាសាសនាដ៏ត្រឹមត្រូវ។ ហេតុនេះ ចូរពួកអ្នកកុំបំពាន ខ្លួនឯងនៅក្នុងខែបម្រាមទាំងនេះ។



وعَنِ ابنِ عَبَّاسٍ رَضِيَ اللَّه عنْهُمَا ، قَالَ : قالَ رسُول اللَّهِ صَلّى اللهُ عَلَيْهِ وسَلَّم : « لَئِنْ بَقِيتُ إِلى قَابِلٍ لأَصُومَنَّ التَّاسِعَ » رواهُ مُسْلِمٌ .

អំពី អ៊ីបនូអាប់ហ្គៀស رضي الله عنهما ថា រ៉សូលុលឡោះ ﷺបានមាន ប្រសាសន៍ថា : " ប្រសិនបើខ្ញុំមានអាយុវែងរហូតដល់ឆ្នាំក្រោយ ខ្ញុំនឹងបួសនៅ ថ្ងៃទី៩(ខែមូហើរ៉ំ)។

Caption

(រាយការណ៍ដោយមូស្លីម)

(Riyad as-Salihin 1253)

وعنْ أَبي قَتَادةَ رضيَ اللَّه عَنْهُ ، أَنَّ رسولَ اللَّهِ صَلّى اللهُ عَلَيْهِ وسَلَّم سُئِلَ عَنْ صِيامِ يَوْمِ عاشُوراءِ ، فَقَال : « يُكَفِّرُ السَّنَةَ المَاضِيَةَ » رواه مُسْلِمٌ .

អំពី អាពូក៏តាហ្ទះ رضي الله عنه ថា : ពិតណាស់រ៉សូលុលឡោះ ﷺត្រូវបានគេសួរ អំពីការបួសថ្ងៃអាសូរ៉ា (ថ្ងៃទី 10 Muharram) ហើយលោកបានមានប្រសាសន៍ឆ្លើយថា : " វានឹងជំរុះ ចោលនូវបាបកម្មក្នុងរយៈពេលមួយឆ្នាំកន្លងមក" (រាយការណ៍ដោយមូស្លីម)

(Riyad as-Salihin 1252)

عَنْ أَبي هُريرَةَ رضيَ اللَّه عَنْهُ ، قالَ : قالَ رَسُولُ اللَّه صلّى الله عَلَيْهِ وسَلَّم : « أَفْضَلُ الصِّيَامِ بعْدَ رَمَضَانَ : شَهْرُ اللَّهِ المحرَّمُ ، وَأَفْضَلُ الصَّلاةِ بَعْدَ الفَرِيضَةِ : صَلاةُ اللَّيْلِ » رواه مسلمُ.

អំពី អាពូហ៊ូរ៉ាយរ៉ោះ رضي الله عنه ថា : រ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ថា : "ការបួសដ៏ល្អបំផុតបន្ទាប់ពីខែរ៉ម៉ាឌន គឺការបួសក្នុងខែមូហើររ៉ំ ហើយការសឡាត ដ៏ល្អបំផុត បន្ទាប់ពីសឡាតដែលជាកាតព្វកិច្ចគឺ ការសឡាតនៅពេលយប់"

(រាយការណ៍ដោយមូស្លីម)

(Riyad as-Salihin 1246)



~Muḥarram គឺជាខែទី 1 របស់អីស្លាម

~Muḥarram គឺជាខែរបស់អល់ឡោះជាម្ចាស់

(Jami` at-Tirmidhi 740)

~Muḥarram គឺជាខែដ៏ពិសិដ្ឋទាំង 4 ក្នុងចំណោមខែរបស់អីស្លាម (Muharram Rajab Dhul-Qa'dah និង Dhul-Hijjah)

Caption

~Muḥarram គឺជាខែបន្ទាប់ពីខែ Ramadan ដែលទទួលគុណសម្បត្តិបានច្រើនក្នុងការបួស

(Jami` at-Tirmidhi 438)

~Muḥarram គឺជាខែបន្ទាប់ពីខែ Ramadan ដែលគេចូលចិត្តបួស ឬបួសល្អបំផុតសំរាប់អ្នកអីស្លាម

(Sunan Ibn Majah 1742)

~Muḥarram មានថ្ងៃ Ashura ដែលអ្នកអីស្លាមធ្វើការបួស ហើយថ្ងៃ Tasu'a' ជាថ្ងៃដែលគេតំរូវឲ្យបួសផងដែរ

~Ashura ក្លាយជាជំរើសសំរាប់អ្នកអីស្លាមក្នុងការបួស ឬមិនបួសបន្ទាប់ពីខែ Ramadan ត្រូវបានគេដាក់កាតព្វកិច្ចបួស

~Muḥarram ប្រការដែលមាននៅក្នុងខែនេះ៖

1.ខែដ៏ពិសិដ្ឋ

2.បួសថ្ងៃ Ashura ឬ ថ្ងៃទី 9th and 10th days of Muharram

3.ហាមឃាត់ការបង្ហូរឈាម ឬធ្វើសង្គ្រាមនៅខែនេះ

4.អនុវត្តប្រការល្អ រំលឹកចំពោះអល់ទ្បោះជាម្ចាស់ឲ្យបានច្រើន ធ្វើការបរិច្ចាគទាន ការបួស ជាដើម

5.មិនត្រូវប្រព្រឹត្តអំពើអាក្រក់ក្នុងខែនេះទ្បើយពីព្រោះបាបកម្មក្នុងខែនេះមានផលអាក្រក់ខ្លាំងជាងខែដ៏ទៃ (... so wrong not yourselves therein …)
(Al-Qur'an 9:36)

6.ធ្វើការបួសស៊ុណ្ណះឲ្យបានច្រើនក្នុងខែនេះព្រោះវាជាខែមួយបន្ទាប់ពីខែ Ramadan ហើយនឹងទទួលបានផល បុណ្យបានច្រើន



Caption

~ʿĀshūrāʾ ថ្ងៃបុណ្យរបស់អ្នកអីស្លាម

~ʿĀshūrāʾ ជាថ្ងៃទី 10 Muharram

~Tasu'a' ជាថ្ងៃទី 9 Muharram (យោងទៅតាមអ្នកប្រាជ្ញអីស្លាម)

~ʿĀshūrāʾ ជាថ្ងៃដែលគេតំរូវឲ្យបួស

~ʿĀshūrāʾ ជាថ្ងៃដែលសំខាន់មួយដោយសារអល់ឡោះបានផ្តល់ការលុបលាងបាបកម្ម ចំពោះខ្លួនយើងរយៈពេលមួយឆ្នាំកន្លងមកក្នុងការបួសនៅថ្ងៃនោះ ។
(Riyad as-Salihin 1252)

~ʿĀshūrāʾ ក៏ជាថ្ងៃដែលពួកពហុទេពនិយមអារ៉ាប់បានលើកតំកើងផងដែរ

And on that day the Ka‘bah used to be covered with a cover’. [Bukhari]

~ʿĀshūrāʾ បួសនៅថ្ងៃនោះ គឺនឹងជំរុះចោលនូវបាបកម្មក្នុងរយៈពេលមួយឆ្នាំកន្លងមក



~ʿĀshūrāʾ មិនមែនជាថ្ងៃសំរាប់ប្រារព្ធពិធីនោះទេពីព្រោះរ៉ស៊ូលុលឡោះ ﷺ បានប្រើឲ្យបួសនៅថ្ងៃនោះ

~ʿĀshūrāʾ ធ្លាប់បានគេដាក់កាតព្វកិច្ចឲ្យបួសនៅថ្ងៃនោះ

~ʿĀshūrāʾ បន្ទាប់ពី Hijrah ត្រូវបានរ៉ស៊ូលុលឡោះ ﷺ ដាក់ជាកាតព្វកិច្ច

Caption

~ʿĀshūrāʾ ត្រូវបានរ៉ស៊ូលុលឡោះ ﷺ ប្រើឲ្យបួស ព្រោះថាអ្នកអីស្លាមជិតទៅចំពោះណាពី្ជ Musa ជាងពួក Jews

~ʿĀshūrāʾ ត្រូវបាន Jews of Khaybar ធ្វើការប្រារព្ធពិធីអបអរ ហើយស្រ្តីរបស់ពួកគេពាក់ទៅដោយគ្រឿងអលង្ការ និងសញ្ញាផ្សេងៗនៅថ្ងៃនោះ ។ ដូចនេះរ៉ស៊ូលុលឡោះ ﷺ បានបញ្ជាឲ្យអីស្លាមបួសនៅថ្ងៃនោះ ។

~ʿĀshūrāʾ ត្រូវបានគេហៅថាជាថ្ងៃសង្គ្រោះ និងជាថ្ងៃសាកល្បង ដោយសារថ្ងៃនោះបណ្តាណាពី្ជ ក្រុមគ្រួសាររបស់គាត់ និងអ្នកដើរតាមៗបានទទួលការសាកល្បង ឬសង្គ្រោះដូចដែលបានចារទុកក្នុងប្រវត្តិសាស្រ្តរួចមកហើយ ។

~ʿĀshūrāʾ ការបួសនៅថ្ងៃនោះ (ទី 10 Muharram) តែ 1 ថ្ងៃវាមិនមែនជាប្រការ makruh (មិនចង់បាន) នោះទេ

~ʿĀshūrāʾ ដែលត្រូវនឹងថ្ងៃសុក្រ ឬថ្ងៃសៅរ៍ការបួសថ្ងៃនោះមិនមែនជាប្រការ makruh ដែលគេមិនពេញចិត្តនោះទេ ។ ចូរបួសពីព្រោះថា Jews បានយកថ្ងៃសៅរ៍ជាថ្ងៃពិសិដ្ឋ ។

~ʿĀshūrāʾ មិនមែនជាថ្ងៃសំរាប់រំលែកទុក្ខ និងជាថ្ងៃប្រារព្ធពិធីនោះទេ



~ការបួសចំនួន 2 ថ្ងៃ គឺថ្ងៃទី 9 និងទី 10 Muharram ដើម្បី៖

» រ៉ស៊ូលុលឡោះ ﷺ មានប្រាថ្នាចង់បួសនៅថ្ងៃទី 9 Muharram ផងដែរ
»ជៀសវាងអំពីប្រពៃណី Jews បួសតែ 1 ថ្ងៃ
»ការចង់បាន និងការយល់ព្រមរបស់អ្នកប្រាជ្ញអីស្លាម

Caption

~Ibn Taymiyyah បាននិយាយថា៖ ការជ្រះស្អាត
ការសឡាត ការបួសខែ Ramadhan ការបួសថ្ងៃ ‘Arafah
ការបួសថ្ងៃ 'Ashura' នឹងលុបលាងបាបកម្មតូចប៉ុណ្ណោះ
[Al-Fatawa al-Kubra, part 5]

~ʿĀshūrāʾ និង 'Arafah ការបួសទាំង 2 ថ្ងៃត្រូវនេះត្រូវបានគេយល់ច្រឡំថាវាជាកិច្ចការសំខាន់ និងអាចលុបលាងបាបកម្មបានជាជាងការបួសខែ Ramadhan និងការសឡាតកាតព្វកិច្ច 5 ដងក្នុង 1 ថ្ងៃ៖

»Ibn al-Qayyim បាននិយាយថា ៖

“មនុស្សដែលបានគិតខុសមិនដឹងថាការតមអាហារនៅខែ Ramadhan និងសឡាត កាតព្វកិច្ច 5 ដងក្នុង 1 ថ្ងៃ គឺសំខាន់ជាងការបួសនៅថ្ងៃ 'Arafah និង 'Ashura' ហើយវាអាចលុបលាងអំពើបាបរវាង Ramadhan ទៅ Ramadhan មួយទៀត ឬរវាងថ្ងៃ Juma’ah មួយទៅថ្ងៃ Juma’ah មួយទៀតដរាបណាពួកគេជៀសពីអំពើបាបធំៗ ។ ទោះជាយ៉ាងណាគេមិនអាចរួចផុតពីអំពើបាបតូចតាចបានឡើយលុះត្រាតែគេជៀសពីអំពើបាបធំៗ ហើយនៅពេលដែលអំពើទាំងពីរនេះបានធ្វើរួមគ្នា គឺអាច លុបលាងបានតែអំពើបាបតូចៗ ប៉ុណ្ណោះ ។

[Al-Mawsu'ah al-Fiqhiyyah, part 31, Ghurur]

~ʿĀshūrāʾ ប្រការដែលអនុវត្តដូចខាងក្រោមនៅថ្ងៃនោះ ដូចជា៖



»ការរៀបចំអាហារសំរាប់ធ្វើពិធី

Caption

»ការស្លៀកពាក់សំលៀកបំពាក់ថ្មី

»ការបរិច្ចាគ

»ការគោរពសក្ការះជាពិសេសមួយ

»ការរក្សាទុកសាច់សត្វគួរបានដើម្បីចំអិនជាមួយគ្រាប់ធញ្ញជាតិ

»ការលាប kohl ឬ henna

»ការមុជទឹក ghusl

»ការចាប់ដៃគ្នាទៅវិញទៅមក

»ការទៅសួរសុខទុក្ខគ្នាទៅវិញទៅមក

»ការទៅទស្សនៈកិច្ចង Masjid ឬទីសក្ការបូជា (shrines) ផ្សេងៗ ។

>ទាំងនេះជាការខុស និង bid'ah ដែលមិនអាចប្រកែកបាន ហើយទាំងនេះមិនមែនជាប្រការស៊ុណ្ណះ និងជាមាគ៌ារបស់ Khulafa' ar-Rashidun សំរាប់អនុវត្តក្នុងថ្ងៃនោះទេ ហើយក៏គ្មានអ្នកប្រាជ្ញអ៊ីស្លាមណាមួយយល់ព្រមនោះដែរ ដូចជា Imam Malik, ath-Thawri, al-Layth ibn Sa'ad, Abu Hanifah, al-Awza'i, al-Shafi'i, Ahmad ibn Hanbal, Ishaq ibn Rahwayh ជាដើម

(Al-Fatawa al-Kubra by Ibn Taymiyyah)

~ការបួសរបស់អ៊ីស្លាមកើតមានជា 3 ទំរង់ និងមានការទាក់ទងនឹងថ្ងៃ ʿĀshūrāʾ ផងដែរ៖

1.នៅពេលរ៉ស៊ូលុលឡោះ ﷺ បានមកដល់ក្រុង Madinah គាត់បានប្រើឲ្យអ្នកអ៊ីស្លាមបួសចំនួន 3 ថ្ងៃរៀង រាល់ខែ

2.និងបួសនៅថ្ងៃ ʿĀshūrāʾ

3.ហើយបន្ទាប់អល់ឡោះជាម្ចាស់ដាក់បួសជាកាតព្វកិច្ច

" … observing the fasting is prescribed for you … " [Al-Qur'an 2:183]



Caption

~ʿĀshūrāʾ មានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដូចជា៖

1.(Jews) ជាថ្ងៃដែលក្រុម Jews បានប្រារព្ធពិធីបុណ្យ និងបួស

2.(Islam) ជាថ្ងៃដែលអ៊ីស្លាមកំណត់ឲ្យបួស និងជាស៊ុណ្ណះ

3.(Ahlul-Bayt) ជាថ្ងៃដែល Ḥusayn ត្រូវបានគេសំលាប់ (Martyrdom of Ḥusayn៖ នៅថ្ងៃសុក្រទី 10 Muharram AH ដែលត្រូវនឹងថ្ងៃទី 10th October ឆ្នាំ 680 គស នៅអាយុ 56 ឆ្នាំ)

4.(Nabi Musa) ជាថ្ងៃដែលអល់ឡោះបានរំដោះអំបូរអ៊ីស្រាអែលអំពី Pharaoh ឬថ្ងៃដែលអល់ឡោះជាម្ចាស់ញែកទឹកសមុទ្រសង្គ្រោះណាព្វី Musa និងអំបូរអ៊ីស្រាអែល [Qur’an, 26:63-66]

5.(Nabi Adam) ជាថ្ងៃដែលអល់ឡោះជាម្ចាស់ទទួលយកការសុំខមាលទោស (ការ Taubah) របស់ណាពី្ព Adam (រាយការណ៍ដោយ Ibn Rajab)

6.(Nabi Nuh) ជាថ្ងៃដែលអល់ឡោះជាម្ចាស់បានសង្គ្រោះណាពី្ព Nuh និងអ្នកនៅលើសំពៅដើម្បីឲ្យពួកគេបានចុះចតនៅលើភ្នំ Judi (Mount Judi)

[Tafsir Ibn Kathir]

سورة هود:44

ហើយទ្រង់បានមានបន្ទូលថាៈ ឱដី! ចូរឯងលេបទឹករបស់ ឯងវិញចុះ។ ឱមេឃ! ចូរឯងឈប់ភ្លៀងទៅ។ ពេលនោះទឹកក៏បាន ស្រកចុះ។ ហើយបទបញ្ជានោះត្រូវបានគេសម្រេច(បានកំទេចអ្នក គ្មានជំនឿពីក្រុមរបស់នូហ) ហើយសំពៅនោះក៏បានចតនៅលើភ្នំជូទី(នៅរវាងប្រទេសអ៊ីរ៉ាក់និងអាម៉េនី)។ ហើយទ្រង់បានមាន បន្ទូលបន្តទៀតថាៈ មហន្តរាយចុះចំពោះក្រុមដែលបំពាននោះ។



7.(Nabi Ayyub) ជាថ្ងៃដែលអល់ឡោះជាម្ចាស់បានសង្គ្រោះគាត់អំពីការសាកល្បងដ៏យូរអង្វែងអំពីការបាត់បង់ក្រុមគ្រួសារ ទ្រព្យសម្បត្តិ និងសុខភាពរបស់គាត់ដោយគាត់តែងតែមានការអត់ធ្មត់ និងជំនឿជានិច្ច ។ (Al-Jilani)

Caption

8.(Nabi Sulayman) ជាថ្ងៃដែលអល់ឡោះជាម្ចាស់បានផ្តល់ឲ្យគាត់នូវអាណាចក្រមួយដែលគ្មានអ្នកណាម្នាក់ទទួលបានបន្ទាប់ពីគាត់ ហើយគាត់អាចបញ្ជាខ្យល់ ទាហាននៃមនុស្ស និងជិន សត្វស្លាប និងសត្វផ្សេងៗទៀតជាដើម ។

(Al-Jilani)

9.(Nabi Yunus) ជាថ្ងៃដែលអល់ឡោះជាម្ចាស់បានយកគាត់ចេញអំពីពោះត្រីបាឡែន និងលើកលែងទោសចំពោះប្រជាជនរបស់គាត់នូវសកម្មភាពរបស់ពួកគេ ។ (Al-Jilani)

10.(Nabi Isa) ជាថ្ងៃដែលអល់ឡោះជាម្ចាស់បានលើកគាត់ទៅឋានសួគ៌ ។ (Al-Jilani)